ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ

# សេចក្តីជូនដំណឹង

ក្រសួងមុខងារសាធារណៈ សូមជម្រាបជូន ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការទាំងអស់មេត្តាជ្រាបថា លោក ប៉ូល វល័ក្ខ ដែលត្រូវជាប្អូនប្រុសបង្កើត **ឯកឧត្តម ប៉ូល ពីឌូ** រដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ បានទទួលមរណភាពនៅថ្ងៃពុធ ១១រោច ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២២ វេលាម៉ោង ២៣:១០នាទី ក្នុងជន្មាយុ៤៩ឆ្នាំ ដោយរោគាពាធ។

**លោក នួន សុខុម** ប្រធានមន្ទីរមុខងារសាធារណៈខេត្តសៀមរាប តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ហ៊ុំ សុខា** រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ នឹងអញ្ជើញចូលរួមគោរពវិញ្ញាណក្ខន្ធ នៅរសៀលថ្ងៃសុក្រ ទី២៣ ខែកញ្ញា ឆ្នាំ២០២២ នៅវត្តត្រពាំងស្វាយ ស្ថិតនៅភូមិគោកដូង សង្កាត់ទឹកវិល ក្រុងសៀមរាប ខេត្តសៀមរាប ផ្លូវទៅព្រលានយន្តហោះអន្តរជាតិខេត្តសៀមរាប។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូម ឯកឧត្តម លោកជំទាវ លោក លោកស្រី មេត្តាជ្រាប ជាព័ត៌មាន និងចូលរួមរំលែកទុក្ខ ព្រមទាំងចាប់មគ្គផលតាមសទ្ធាជ្រះថ្លារៀងៗខ្លួន។
**ឯកឧត្តម ប៉ូល ពីឌូ “PAUL PIDOU”** មានគណនី ABA លេខ 000 849 739 ( ដុល្លារ )
Canadia Bank លេខ 048 000 001 5786 ( ខ្មែររៀល )

ថ្ងៃព្រហស្បតិ៍ ១២រោច ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២២

ក្រសួងមុខងារសាធារណៈ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ

# លិខិតរំលែកមរណទុក្ខ

**ជូនចំពោះ**

**ឯកឧត្តម ប៉ូល ពីឌូ រដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ និងក្រុមគ្រួសារ**

ខ្ញុំ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការទាំងអស់ នៃក្រសួងមុខងារសាធារណៈ មានសេចក្តីសោកស្តាយជាពន់ពេក ដោយបានទទួលដំណឹងថា **លោក ប៉ូល វល័ក្ខ** ដែលត្រូវជាប្អូនប្រុសបង្កើតរបស់ **ឯកឧត្តម** បានទទួលមរណភាពកាលពីថ្ងៃពុធ ១១រោច ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២២ វេលាម៉ោង ២៣:១០នាទី ក្នុងជន្មាយុ ៤៩ឆ្នាំ ដោយរោគាពាធ។

ស្ថិតក្នុងវេលាពោរពេញដោយក្តីរន្ធត់ចិត្ត និងសមានទុក្ខដ៏ក្រៀមក្រំនេះ ខ្ញុំ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការទាំងអស់ នៃក្រសួងមុខងារសាធារណៈ សូមចូលរួមសម្តែងនូវសេចក្តីសោកស្តាយ ស្រណោះ អាឡោះអាល័យបំផុតជាមួយ **ឯកឧត្តម និងក្រុមគ្រួសារ** ចំពោះការបាត់បង់ **លោក ប៉ូល វល័ក្ខ** ដែលជាប្អូនប្រុសបង្កើតប្រកបដោយព្រហ្មវិហារធម៌ និងសង្គហធម៌ដ៏ល្អប្រពៃរបស់ក្រុមគ្រួសារ។

យើងខ្ញុំទាំងអស់គ្នា សូមឧទ្ទិសបួងសួងជូនវិញ្ញាណក្ខន្ធ **លោក ប៉ូល វល័ក្ខ** បានអញ្ជើញទៅកាន់សុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។

សូម **ឯកឧត្តម និងក្រុមគ្រួសារ** ទទួលនូវការរំលែកទុក្ខដ៏ក្រៀមក្រំបំផុតពីយើងខ្ញុំ៕

ថ្ងៃព្រហស្បតិ៍ ១២រោច ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២២ ខែ កញ្ញា ឆ្នាំ២០២២

**តំណាងថ្នាក់ដឹកនាំនិងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈ**

**រដ្ឋមន្ត្រី**

ព្រំ-សុខា